# គំរូចិន

ចិន កុម្មុយនិស្ត សព្វថ្ងៃ ជា មហាអំណាច នៃ សេដ្ឋកិច្ច ពិភពលោក មួយ ដោយសារ ខ្លួន យក ប្រព័ន្ធ មូលធននិយម មកអនុវត្ត នៅក្នុង វិស័យ សេដ្ឋកិច្ច សេរី ដោយ បោះបង់ចោលការតស៊ូ វណ្ណៈ និង មនោគមវិជ្ជា ដែល ជា ឧបសគ្គ ដល់ ការធ្វើអភិវឌ្ឍន៍ សេដ្ឋកិច្ច នៅក្នុង ក្រខណ្ឌ លោកូបនីយកម្ម។ ការប្រែផ្លាស់ នេះ មាន ល្បឿន លឿនណាស់ នៅ ក្រោម ការដឹកនាំរបស់ លោក Deng Xiaoping (១៩៧៨-១៩៩២)[1]។ គេ ដឹង ថាប្រព័ន្ធ នយោបាយ មូលធននិយម មាន គោលការណ៍ សំខាន់បី យ៉ាង : ទី១ រដ្ឋ ស្ថិត នៅក្រោម ឥទ្ធិពល ការិយាល័យធិតេយ្យនៃ បច្ចេកទេស ដែល ជា មូលដ្ឋាន នៃ កំណើន សេដ្ឋកិច្ច សេរី។ទី២ រដ្ឋ មាន ច្បាប់ សំរាប់ អនុវត្ត, តែ ច្បាប់ នោះ ជួនកាល ត្រូវបាន ពួក ឥស្សរជន យក មក អនុវត្ត តាម អំពើចិត្ត ដើម្បីការពារ ផលប្រយោជន៍ របស់ ពួក ខ្លួន ឬ ក៏ បដិសេធ មិនព្រមអនុវត្ត នៅ ពេល ដែល ច្បាប់ នោះ វា ផ្ទុយនឹង ផលប្រយោជន៍របស់ ខ្លួន ឬ យក ច្បាប់ នោះ មក អនុវត្ត យ៉ាង តឹងរ៉ឹង បំផុតសំរាប់ ប្រឆាំងនឹង ប្រតិបក្ស ទាំងឡាយ របស់ ខ្លួន។ ទី៣ រដ្ឋត្រូវ មាន ស្វ័យភាព ចាំបាច់ សំរាប់ ធ្វើ សកម្មភាព ដែល ត្រូវ

[1] ប្រទេស ចិន សព្វថ្ងៃ ជា សមាជិក នៃ អង្គការ ពិភពលោក នៃ ពាណិជ្ជកម្ម (OMC)។

តែ ធ្វើ ជា ដាច់ខាត សំរាប់ ការពារ ប្រយោជន៏ រួម, ដូច្នេះ រដ្ឋ ត្រូវ ផុតចាក ពី កំហិត នៃ ច្បាប់។ ទំនាស់ នៃ គោលការណ៏ ទី១ នឹង ទី២ នាំ បង្កើត អំពើ ពុករលួយ[2] ដែល ជា ផ្នែក សំខាន់ មួយ មាន លក្ខណៈ មិន ធម្មតា នៅក្នុង ប្រព័ន្ធ នៃ នយោបាយ មូលធននិយម។ ក្នុង ចំណុច នៃ លក្ខណៈ មិន ធម្មតា បែប នេះឯង ដែល ជួយ ជំរុញ ដល់ ការលូតលាស់ នៃ ប្រទេស កុម្មុយនិស្ត ចិន និង យួន ជាង ២៧ ឆ្នាំ មកហើយ រហូត មកដល់ ឆ្នាំ ២០១៧ ក្នុង អត្រា កំណើន ជា មធ្យម ៨% នៅ ស្រុកចិន និង ប្រហែល ៧% នៅ ស្រុកយួន បើ ប្រៀបធៀប នឹង សហរដ្ឋអាមេរិក មាន តែ ២% ប៉ុណ្ណោះ។ តែ កំណើន សេដ្ឋកិច្ច ដ៏អស្ចារ្យ របស់ ចិន ក៏ បង្កើន នូវ វិសមភាព ខ្លាំង នោះ ដែរ នៅក្នុង សង្គម។ Coefficient de Gini[3] បង្ហាញ ថា វិសមភាព នៅក្នុង សង្គម របស់ ចិន ពី ឆ្នាំ ១៩៨៥ ដល់ ២០១០ មាន កើនឡើង ពី ០.៣០ ទៅ ០.៥០។ វិសមភាព នេះ មាន នៅ គ្រប់ ទីកន្លែង និង មជ្ឈដ្ឋាន ដែល បង្ហាញ នូវ រូបភាព ច្បាស់ នៃ អ្នកមាន និង អ្នកក្រ នៅក្នុង សង្គម ដែល ផ្ទុយ ពី មនោគមវិជ្ជា នៃ លទ្ធិ កុម្មុយនិស្ត។

---

[2] សព្វថ្ងៃ នៅ ក្រោម ការដឹកនាំ របស់ លោក Xi Jinping រដ្ឋាភិបាល ចិន ចាត់វិធានការណ៍ តឹងរឹង ប្រឆាំងនឹង អំពើ ពុករលួយ។

[3] Le coefficient de Gini, ou indice de Gini, est une mesure statistique permettant de rendre compte de la répartition d'une variable (salaire, revenus, patrimoine) au sein d'une population. Autrement dit, il mesure le niveau d'inégalité de la répartition d'une variable dans la population. ជាវិធី សំរាប់ វាស់ នូវ វិសមភាព នៅក្នុង សង្គម ដោយ ប្រើ វិបរិណាម បី យ៉ាង គឺ បៀវត្ស, ផលទុន និង បេតិកភណ្ឌ របស់ ប្រជាពលរដ្ឋ។

គួរកត់សម្គាល់ ផងដែរ ថា ការកើនឡើង នៃ សេដ្ឋកិច្ចចិន គឺ មាន មក ពី ចំណែក នៃ ប្រាក់ចំណូល របស់ មូលធន ដែល គ្រប់គ្រង ដោយ ឯកជន ធ្វើ សកម្មភាព សេដ្ឋកិច្ច នៅ ក្នុង ទីផ្សារ សេរី នៃ លោកខាងលិច។ ការណ៍ នេះ នាំ បង្កើត មូលធនិក ថ្មី នៅ ស្រុកចិន។ បើ ប្រៀបធៀប ជាមួយ ពួក មូលធនិក នៅ បស្ចិមប្រទេស ពួក មូលធនិក ថ្មី នៅ ស្រុកចិន វា អាច គ្រាន់តែ ជា ក្រុម មួយ ដោយ ខ្លួនឯង ជាង ជា ក្រុម មួយ សំរាប់ ខ្លួនឯង ពី ព្រោះ អំណាច ពិតប្រាកដ វា ស្ថិត នៅក្នុង កណ្តាប់ដៃ នៃ បក្សកុម្មុយនិស្ត - រដ្ឋ។ ដូច្នេះ គេ អាច សន្និដ្ឋាន បាន ថា មូលធននិយមចិន ជា មូលធននិយម ដឹកនាំ ដោយ រដ្ឋ ស្ថិត នៅ ក្រោម ការត្រួតត្រា នៃ បក្សកុម្មុយនិស្តចិន។ អំណាច រឹងមាំ និង មជ្ឈការ របស់ រដ្ឋ នេះឯង ដែល រារាំង ពួក មូលធិនិកចិន មិនអោយ ក្លាយ ជា មជ្ឈមណ្ឌល អំណាច ឯករាជ្យ ពី រដ្ឋ ទោះបី ពួក នោះ រួមចំណែក យ៉ាងសកម្ម ក្នុង ការ ធ្វើអភិវឌ្ឍសេដ្ឋកិច្ច។ ជា ពិសេស ពួក នោះ គ្មាន សិទ្ធិ និយាយ អ្វី បាន ជា ដាច់ខាត នៅ ក្នុង វិស័យ នយោបាយ ដែល ជា វិស័យ បំរុកទុក សំរាប់ តែ បក្សកុម្មុយនិស្តចិន។ នៅពេល ដែល ចិន ពង្រីក តួនាទី របស់ ខ្លួន នៅលើ ឆាក អន្តរជាតិ, ឈរ លើ គំរូ សេដ្ឋកិច្ច របស់ ខ្លួន, ចិន ជួបប្រទះ ទំនាស់ ជាមួយ នឹង មូលធននិយម នៃ មស្ចឹមប្រទេស ដែល មាន មូលដ្ឋាន ផ្អែក លើ ស្នាដៃការងារសមល្អ ដោយ សេរី (méritocratie libérale)។ អត្ថប្រយោជន៍ នៃ មូលធននិយម សេរី មាន នៅក្នុង ប្រព័ន្ធ

## គំរូចិន

នយោបាយ នៃ លទ្ធិប្រជាធិបតេយ្យ សេរី រីឯ មូលធននិយម ចិន ស្ថិត នៅក្នុង ប្រព័ន្ធ នយោបាយ « ភាជន៍ បិទមាត់ » (vase clos)។ ខ្លឹមសារ ផ្ទុយគ្នា នៃ ប្រព័ន្ធ ទាំងពីរ នេះ គឺ លទ្ធិប្រជាធិបតេយ្យ សេរី តម្រូវ អោយមាន ការពិគ្រោះ យោបល់ ជាប្រចាំ របស់ ប្រជាពលរដ្ឋ តាម ការបោះឆ្នោត ដោយ សេរី និងយុត្តិធម៌ ដែល ផ្តល់ នូវ ការកែតម្រូវ នៃ នយោបាយ សេដ្ឋកិច្ច និង សង្គម តាម ការប្តូរ ឬ ការរក្សា គណបក្សដឹកនាំ តាម ឆន្ទៈ របស់ ប្រជាពលរដ្ឋ ដើម្បី ចៀសវាង កុំអោយ បង្ក អន្តរាយ ដល់ ភោគសម្បត្តិ រួម របស់ ប្រជាពលរដ្ឋ។ រីឯ ចិន វិញ ស្ថិត នៅក្នុង ប្រព័ន្ធ នៃ លទ្ធិកុម្មុយនិស្ត តែ នៅក្នុង វិស័យ សេដ្ឋកិច្ច ផ្ទៀត ប្រើ បណ្តាញ នៃ សេដ្ឋកិច្ច ជំនួញ របស់ មូលធននិយម សេរី ដែល ជា ចលករ នៃ ការរីកចំរើន សេដ្ឋកិច្ច របស់ ចិន។ គំរូ ចិន នេះ ទំនង ជា បន្ត អោយ សេដ្ឋកិច្ច ចិន មាន ការរីកចំរើន ដែល នាំ អោយ ចិន មាន លទ្ធភាព អាច នាំចេញ គំរូ សេដ្ឋកិច្ច និង ស្ថាប័ន នយោបាយ របស់ ខ្លួន ទៅ ដាំ នៅក្នុង ប្រទេស ទុនខ្សោយ នៅ អាស៊ី និង អាហ្វ្រិក តាម រយៈ គំនិតផ្តួចផ្តើម មួយ មាន ឈ្មោះ ថា « Belt and Road[4] » ដែល ជា គម្រោង ដ៏ សម្បើម មួយ ដែល ចិន ជា អ្នក ផ្តល់ ហិរញ្ញប្បទាន សំរាប់ ស្ថាបនា ហេដ្ឋារចនាសម្ព័ន្ធ ក្នុង គោលដៅ តភ្ជាប់ រវាង តំបន់ សេដ្ឋកិច្ច នៅ ក្នុង ប្រទេស នីមួយៗ និង ប្រទេស និង ប្រទេស នៅក្នុង ទ្វីប មួយ។ ការផ្តួចផ្តើម នេះ ជា តំណាង នៃ

[4] Belt and Road : ដំបន់ និង ផ្លូវ។

# គំរូចិន

បញ្ហា ឧត្តមគតិ របស់ លោក ខាងលិច ចំពោះ វិធី ដោះស្រាយ ការអភិវឌ្ឍន៍ សេដ្ឋកិច្ច នៅលើ ពីភពលោក។ ជា ធម្មតា មស្ទី មប្រទេស ផ្តោតគំនិត សំខាន់ ទៅលើ ការសាង ស្ថាប័ន នយោបាយ ជា បឋម, ចំណែកឯ ចិន វិញ ផ្តង់គំនិត ទៅលើ ការស្ថាបនា របស់ ពិត ដែល វា នាំ បង្កើត ទំនាស់ នៃ ទស្សនៈ រវាង លោកសេរី និង ចិនកុម្មុយនិស្ត នៅក្នុង សេដ្ឋកិច្ច ផ្សារ នៅលើ ពិភពលោក។ គំរូ សេដ្ឋកិច្ចចិន ស្វែងរក ការធ្វើ អោយ ប្រសើរ នៅក្នុង ជីវភាព រស់នៅ របស់ ប្រជាជន, រីឯ មូលធន និយម សេរី វិញ ផ្តល់ នូវ សេរីភាព គ្រប់ បែបយ៉ាង ដល់ មនុស្ស លោក ដើម្បី កសាង ដោយ ខ្លួនឯង នូវ សុភមង្គល របស់ ខ្លួន ដែល ខ្លួន ចង់បាន នៅក្នុង ក្របខណ្ឌ នៃ លទ្ធិប្រជាធិបតេយ្យ សេរី ដែល ប្រជាជន ជា អធិបតី។ ភាពជាក់ស្តែង គឺ មូលធន និយម សេរី បាន បង្ហាញ ស្តែង រួចហើយ នូវ ប្រសិទ្ធភាព របស់ ខ្លួន ក្នុងការបង្កើត ភោគសម្ប័ទ ជា ភក្សា ក្តី, សម្ភារៈ ក្តី, បញ្ញា ក្តី សំរាប់ មនុស្សជាតិ, ចំណែកឯ លទ្ធិកុម្មុយនិស្ត វិញ តាម ការ ពិសោធ របស់ ខ្លួន បាន បំផ្លាញ ជីវិត មនុស្ស ជាង មួយ រយ លាន នាក់ នៅលើ ពិភពលោក, រីឯ គំរូ ចិន នៅ ថ្មី ណាស់ ហើយ ស្ទើរកំណើត សំរាប់ បង្ហាញ នូវ ភាពស័ក្តិសិទ្ធ របស់ ខ្លួន នៅ ចំពោះមុខ បញ្ហា នៃ មនុស្សជាតិ។ ត្រូវ ដឹង ថា មនុស្សលោក មិន គ្រាន់ តែ ត្រូវការ ហេដ្ឋារចនាសម្ព័ន្ធ, ផ្ទះសំបែង, អាហារ សំ រាប់ គ្រាន់ តែ រស់នៅ តែ ក៏ ត្រូវការ ផងដែរ សេរីភាព បន្ថែម ទៀត ដើម្បី រស់នៅ ដោយពេញលេញ ជា មនុស្ស ព្រោះ សេរីភាព

**ឥតរូបចិន**

ជា សារជាតិ របស់ ខ្លួន។ ជា ការពិតហើយ ប្រព័ន្ធ នៃ មូលធននិយម សេរី ក៏ មាន គុណវិបត្តិ របស់ ខ្លួន នោះដែរ តែ គុណវិបត្តិ ទាំងឡាយ នោះ ត្រូវ បាន ធ្វើ កំណែ ជា និច្ច តាម ការផ្លាស់ប្តូរ នយោបាយ ដឹកនាំ នៅក្នុង ក្របខណ្ឌ នៃ លទ្ធិប្រជាធិបតេយ្យ សេរី ដូច បាន ជំរាប ខាងលើ រួចមកហើយ៕